**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គាំពារសង្គមកម្ពុជា**

**SOCIAL PROTECTION IN CAMBODIA**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៥៨)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៦ ៣០៣នាក់ នៃរោងចក្រ សហគ្រាសទាំង៣៤ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីងនឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ០០០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២០ ០០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦០ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីងនឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាសទាំង៣៤ នេះ មិនបានទទួលសារទូរសព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

*ថ្ងៃ ច័ន្ទ ១០រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*

*រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមេសា ឆ្នាំ២០២១*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១**

**បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍**
**ចំនួន ៣៤ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 12 |
| 1 | ក្រុមហ៊ុន សេីង យ៉ុង ហ្គាមែនហ្វាត់តូរី ខូអិលធីឌី | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ហ្សាក់ស៊ីនតិច អ៊ីនដាស់ស្ទ្រីស៍ ខេមបូឌា | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ម៉ាក ប៉ែក (ខេមបូឌា) ខូអិលធីឌី | ភ្នំពេញ |
| 4 | ក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ហ្គោលដេនប្រស្តើរហ្វ៊ូតវែរ | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ផុង ឆាវ អេនធើប្រាយ (ខេមបូឌា) អិលធីឌី | ភ្នំពេញ |
| 7 | ក្រុមហ៊ុន អិន ឃីយ៉ុង(ខេមបូឌា) | ភ្នំពេញ |
| 8 | ក្រុមហ៊ុន ហ្គោលហ្វេម ស្តារ អេនធើប្រាយ (ខេមបូឌា) លីមីធីត | កណ្តាល |
| 9 | ក្រុមហ៊ុន ហេង ស៊ីម ហ្វ៊ូតវែរ ឯ.ក | កំពង់ស្ពឺ |
| 10 | ក្រុមហ៊ុន វីននឹង ដ្រាហ្គនឡេតឌឺវែរ(ខេមបូឌា) ខូអិលធីឌី | កំពង់ស្ពឺ |
| 11 | ក្រុមហ៊ុន ហ៊ែលសា សៅអ៊ិសអេស៊ា ខូអិលលធីឌី | ស្វាយរៀង |
| 12 | ក្រុមហ៊ុន វ៉ាន់ធីជ រីវើរ ថេកស្តាយ | ព្រះសីហនុ |
| ខ. វិស័យទេសចរណ៍ | | 22 |
| 13 | សណ្ឋាគារ វ៉ាហ្វិល រ៉ូយ៉ាល់ | ភ្នំពេញ |
| 14 | ក្រុមហ៊ុន អលឌ្រីម (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 15 | សណ្ឋាគារ ហ្គាឌិន ស៊ីធី ហូថេល | ភ្នំពេញ |
| 16 | ក្រុមហ៊ុន កូបេ យៃភែននីស វែស្ទូវែន | សៀមរាប |

| ល.រ | ឈ្មោះគេហដ្ឋាន សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 17 | ក្រុមហ៊ុន រ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 18 | សណ្ឋាគារ លីនាយាអង្គរ រីសត និងស្ប៉ា | សៀមរាប |
| 19 | ក្រុមហ៊ុន ទន្លេសាបថៅផាយ៉ា( អង្គរធីខេត្រាវែល ធូរ) | សៀមរាប |
| 20 | ភោជនីយដ្ឋាន នារីខ្មែរ | សៀមរាប |
| 21 | សណ្ឋាគារ តារា អង្គរ | សៀមរាប |
| 22 | សណ្ឋាគារ វីណាហ្គហ្វ អង្គរ | សៀមរាប |
| 23 | សណ្ឋាគារខេមរាអង្គរ | សៀមរាប |
| 24 | សណ្ឋាគារ វិរតន៍ | សៀមរាប |
| 25 | ក្រុមហ៊ុន វិរតន៍ វីឡា | សៀមរាប |
| 26 | ក្រុមហ៊ុន ផ្កាចន្ទន៍ សៀមរាប យ៉ុងឆាង | សៀមរាប |
| 27 | ភោជនីយដ្ឋាន វិរតន៍ | សៀមរាប |
| 28 | សណ្ឋាគារ សិន្តា មុន្នី | សៀមរាប |
| 29 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 30 | ក្រុមហ៊ុន អង្គរតែលេសរីហ្សត និងស្ប៉ា | សៀមរាប |
| 31 | ក្រុមហ៊ុន អញ្ជលី បាយ ស៊ីធុន | សៀមរាប |
| 32 | ក្រុមហ៊ុន ខ្មែរអង្គរហូថែលកូអិលធីឌី | សៀមរាប |
| 33 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 34 | សណ្ឋាគារប៉ាក់ឌីសអង្គរវីឡា | សៀមរាប |